ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

*ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៥*

## សេចក្តីប្រកាសអំពីការតែងតាំង លោកស្រី Tennealle O'Shannessy ជាអ្នកធុរកិច្ចឆ្នើម

ជាផ្នែកមួយនៃការប្តេជ្ញារបស់ប្រទេសអូស្ត្រាលី ក្នុងការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចជាមួយអាស៊ីអាគ្នេយ៍ លោកស្រី Tennealle O'Shannessy នាយិកាប្រតិបត្តិនៃ IDP Education ត្រូវបានតែងតាំងជា អ្នកធុរកិច្ចឆ្នើមអូស្ត្រាលីថ្មីប្រចាំនៅកម្ពុជា។

ក្នុងតួនាទីនេះ លោកស្រី O'Shannessy នឹងប្រើប្រាស់ជំនាញ និងទស្សនវិស័យសកលរបស់លោកស្រី ដើម្បីពង្រីកទំនាក់ទំនងសេដ្ឋកិច្ចយូរអង្វែងរបស់យើង តាមរយៈការជំរុញឱកាសពាណិជ្ជកម្ម និងការវិនិយោគរបស់អូស្ត្រាលីនៅកម្ពុជា។

លោកស្រី O'Shannessy បានមានប្រសាសន៍ថា លោកស្រីមានកិត្តិយសណាស់ដែលត្រូវបានតែងតាំងជាអ្នកធុរកិច្ចឆ្នើមអូស្ត្រាលីប្រចាំនៅកម្ពុជា។

លោកស្រី O'Shannessy បានមានប្រសាសន៍ថា "ខ្ញុំមានសេចក្តីរីករាយក្នុងការទទួលយកតួនាទីនេះ។ ជាងបីទសវត្សរ៍កន្លងមកនេះ IDP បានឃើញដោយផ្ទាល់នូវអត្ថប្រយោជន៍ដ៏ច្រើនដែលកើតចេញពីការបង្កើតទំនាក់ទំនងវប្បធម៌ និងសេដ្ឋកិច្ចដ៏រឹងមាំជាមួយប្រទេសកម្ពុជា"។ លោកស្រីបានបន្តទៀតថា "ខ្ញុំរំពឹងថានឹងជំរុញឱកាសធុរកិច្ចដែលស្ថាបនាចេញពីមូលដ្ឋាននេះ និងរួមចំណែកដល់វិបុលភាពរួមគ្នារបស់យើង"។

ការតែងតាំងលោកស្រីជាអ្នកធុរកិច្ចឆ្នើម គឺជាផ្នែកមួយនៃការអនុវត្តការវិនិយោគៈ យុទ្ធសាស្ត្រសេដ្ឋ-កិច្ចតំបន់អាស៊ីអាគ្នេយ៍របស់អូស្ត្រាលីដល់ឆ្នាំ ២០៤០ ដែលកំណត់ឱកាសសំខាន់ៗសម្រាប់ការពង្រីកពាណិជ្ជកម្ម និងការវិនិយោគនៅទូទាំងអាស៊ីអាគ្នេយ៍។

យុទ្ធសាស្ត្រសេដ្ឋកិច្ចតំបន់អាស៊ីអាគ្នេយ៍របស់អូស្ត្រាលី "Invested" បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការសហការរវាងរដ្ឋាភិបាល និងធុរកិច្ច និងបញ្ជាក់ពីឱកាសសម្រាប់ការចូលរួមផ្នែកសេដ្ឋកិច្ចកាន់តែច្រើនជាងមុនរវាងអូស្ត្រាលី និងកម្ពុជា នៅលើវិស័យអប់រំ និងជំនាញ កសិកម្ម និងអាហារ ការផ្លាស់ប្តូរថាមពលបៃតង និងហេដ្ឋារចនាសម្ព័ន្ធ។

កម្ពុជា និងអូស្ត្រាលីចែករំលែកភាពជាដៃគូយូរអង្វែង ជាពិសេសលើវិស័យអប់រំ។ IDP គឺជាអ្នករួមចំណែកដ៏គួរឱ្យទុកចិត្តដល់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជាអស់រយៈពេលជាង ៣០ ឆ្នាំមកហើយ ដោយបានជួយដល់ប្រជាជនកសាងជំនាញដែលចាំបាច់សម្រាប់ការរីកចម្រើនក្នុងសេដ្ឋកិច្ចសកល។

លោកស្រី O'Shannessy បន្តថា "តាមរយៈការអប់រំ និងជំនាញ យើងកំពុងជួយបណ្តុះបណ្តាលសមត្ថ-ភាពសម្រាប់អ្នកដឹកនាំ អ្នកជំនាញអាជីព និងសហគ្រិនជំនាន់ថ្មីរបស់កម្ពុជា"។

តាមរយៈកម្មវិធីសិក្សាអន្តរជាតិ ការសិក្សាភាសាអង់គ្លេស និងប្រព័ន្ធធ្វើតេស្តសាកល្បងភាសាអង់គ្លេសអន្តរជាតិ (IELTS) IDP គាំទ្រការអភិវឌ្ឍកម្លាំងការងារដែលមានជំនាញ ដែលអាចជំរុញកំណើនសេដ្ឋ-កិច្ចនាពេលអនាគតរបស់កម្ពុជា។

យើងរំពឹងថានឹងបានធ្វើការកាន់តែជិតស្និទ្ធជាមួយ លោកស្រី O'Shannessy ដើម្បីលើកស្ទួយពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី និងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកាន់តែជិតស្និទរវាងប្រទេសយើងទាំងពីរ។

**ទំនាក់ទំនងព័ត៌មាន :** Media.Cambodia@dfat.gov.au